**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

ថ្ងៃ ចន្ទ ១០ រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១៣ ឆ្នាំ២០២៦ ស្តីពី
## "ការលើកកម្ពស់ផលិតកម្មក្នុងស្រុក និងការជំនួសផលិតផលនាំចូល ប្រកបដោយចីរភាព"

៙៙៙✷៚៚៚

ផលិតកម្មក្នុងស្រុកត្រូវបានចាត់ទុកជាកម្លាំងចលករក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ចប្រកបដោយចីរភាព ជាពិសេសនៅក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកកំពុងតែប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពលើផលិតកម្មក្នុងស្រុកតាមរយៈគំនិតផ្តួចផ្តើមជាច្រើន រួមមាន ការបណ្តុះបណ្តាលសហគ្រិនភាពដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ព្រមទាំងសហគ្រិនស្ត្រី ការធ្វើកំណែទម្រង់ការចុះបញ្ជីអាជីវកម្ម ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យា និងការដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តជាច្រើនផ្សេងទៀត។ ការកើនឡើងនៃការផលិតក្នុងស្រុកនឹងរួមចំណែកយ៉ាងសំខាន់ដល់ការជំនួសការនាំចូលលើផលិតផលណាដែលមានវត្ថុធាតុដើមហើយអាចផលិតក្នុងស្រុកបាន ដែលនឹងបង្កើតការងារ និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ទោះយ៉ាងណា ការជំរុញផលិតកម្មក្នុងស្រុកនៅតែមានបញ្ហាប្រឈមជាច្រើនដែលទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធរួមចំណែកដោះស្រាយបន្ថែមទៀត។ ដោយពិនិត្យឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជានឹងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី១៣ សម្រាប់ឆ្នាំ២០២៦ក្រោមប្រធានបទគោល ស្តីពី "ការលើកកម្ពស់ផលិតកម្មក្នុងស្រុក និងការជំនួសផលិតផលនាំចូល ប្រកបដោយចីរភាព"។

បេក្ខជនដែលមានចំណាប់អារម្មណ៍អាចផ្ញើសំណើស្រាវជ្រាវមកកាន់នាយកដ្ឋាននយោបាយរូបិយវត្ថុនិងស្រាវជ្រាវ តាមរយៈអ៊ីម៉ែល macroconfer@nbc.gov.kh ឬទំនាក់ទំនងមកកាន់លេខទូរស័ព្ទ (៨៥៥) ១១ ៦១១ ២១៧/ ១៥ ២៥៦ ១៦៦ សម្រាប់ព័ត៌មានដែលពាក់ព័ន្ធនឹងសន្និសីទនេះ។

### កាលបរិច្ឆេទសំខាន់ៗ៖

- ការផុតកំណត់នៃការទទួលសំណើស្រាវជ្រាវ (១-៣ទំព័រ) ៖ **ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦**
- ការជូនដំណឹងស្តីពីសំណើស្រាវជ្រាវដែលត្រូវបានជ្រើសរើស៖ **ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦**
- ការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១៣៖ **ខែវិច្ឆិកា ឆ្នាំ២០២៦។**

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧